00640380

E26

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 01 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# ដីកាកំណត់កាលបរិច្ឆេទសវនាការរួមលើសំណើសុំឲ្យដោះលែង

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
សា សុវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

**បានឃើញ** សំណើសុំដោះលែងឱ្យមានសេរីភាពយោងតាមវិធាន ៨២ (៣) នៃវិធានផ្ទៃក្នុង ដែលបានដាក់ដោយមេធាវីរបស់ ខៀវ សំផន នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១១ សំណើសុំដោះលែង នួន ជា ជាបន្ទាន់ដែលបានដាក់ដោយមេធាវីរបស់ នួន ជា នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ និងសំណើបន្ទាន់ដើម្បីឱ្យដោះលែងអ្នកស្រី អៀង ធីរិទ្ធ ដោយឥតបង្អង់ ដែលបានដាក់ដោយមេធាវីរបស់ អៀង ធីរិទ្ធ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ ("សំណើសុំ")។

**អនុលោម** តាមវិធាន ៧៩ និងវិធាន ៨២ នៃវិធានផ្ទៃក្នុង។

## ហេតុដូច្នេះសម្រេច

**ទទួល** យកសំណើសុំរបស់មេធាវីការពារក្តីទាំងអស់ ដើម្បីដាក់ជេញដោលដោយផ្ទាល់មាត់ក្នុងសវនាការរួមដែលនឹងប្រព្រឹត្តទៅជាសាធារណៈនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ នៅបន្ទប់សវនាការធំនៃ អ.វ.ត.ក ចាប់ពីម៉ោង ៨ និង ៣០ នាទីព្រឹក តទៅ។

មេធាវីរបស់ជនជាប់ចោទនីមួយៗមានរយៈពេលជាអតិបរមាចំនួន ៣០ នាទី ដើម្បីធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងសំណើសុំរបស់ខ្លួន លើកលែងតែមេធាវីដែលបានបញ្ជាក់ថា ខ្លួនមានបំណងធ្វើការបង្ហាញនូវមូលហេតុទាំងនេះក្នុងសារណាជាលាយលក្ខអក្សរតែប៉ុណ្ណោះ ។ ដោយបានទទួលនូវសំណើជាលាយលក្ខអក្សរ អង្គជំនុំជម្រះនឹងអញ្ជើញមេធាវីរបស់ជនជាប់ចោទដែលពាក់ព័ន្ធឡើងធ្វើការឆ្លើយបំភ្លឺនូវសំណួរដូចខាងក្រោម ក្នុងពេលសវនាការ៖

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេច បន្តចិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

១. តើអ្វីទៅដែលជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដោយសារតែសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ មិនមាននូវសំអាងហេតុនោះ?

២. ហេតុអ្វីបានជាអ្នកនិយាយថា ការដោះលែងភ្លាមៗគឺជាសំណងមួយដ៏សមរម្យសម្រាប់ដោះស្រាយនូវការរំលោភលើសិទ្ធិរបស់ជនជាប់ចោទនោះ ?

នៅក្នុងអំឡុងពេលសវនាការ សហព្រះរាជអាជ្ញាអាចធ្វើការឆ្លើយតបដោយផ្ទាល់មាត់ទៅនឹងសំណើរបស់មេធាវីការពារក្ដី ប្រសិនបើខ្លួនមានបំណងធ្វើដូច្នេះ។ សហព្រះរាជអាជ្ញាមានរយៈពេល ៦០ នាទី ដើម្បីធ្វើការឆ្លើយតបទៅនឹងសំណើទាំងនោះ។ បន្ទាប់មក មេធាវីការពារជនជាប់ចោទនីមួយៗមានរយៈពេល ១០ នាទី ដើម្បីធ្វើការឆ្លើយតបវិញ ។

អង្គជំនុំជម្រះកត់សម្គាល់ថា វិធាន៨២(៣)នៃវិធានផ្ទៃក្នុង កំណត់ការចូលរួមសវនាការត្រឹមតែភាគីដែលពាក់ព័ន្ធនឹងសំណើសុំប៉ុណ្ណោះ។ វិធាននេះមិនតម្រូវឱ្យមានការធ្វើការកត់សម្គាល់ពីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏មិនតម្រូវឱ្យមានវត្តមានពួកគេក្នុងសវនាការដែរ។

ដីកាកំណត់កាលបរិច្ឆេទសវនាការដែលបានធ្វើការកែប្រែនេះនឹងធ្វើការផ្លាស់ប្ដូរ និងជំនួសនូវរាល់ដីកាដែលបានចេញពីមុន ដូចជាឯកសារលេខ E18/1 និង E19/1 ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

និល ណុន